# ខ្លាំងមែន

កាកគតិ

បើគិតលេងៗ

| | | |
|---|---|---|
| អ្នករាំតាមភ្លេង | ដូចជាល្ងង់ឆ្កួត | គ្រាន់តែក្ដុងក្ដាំង |
| ញ័រខ្លួនរមួត | ហត់ស្ទើរដាច់សួត | តែគ្មានអ្នកថ្ងូរ។ |
| | ស្អុយញើសឡប់ខ្មៀ | |
| អ្នករាំមិនបែ | រិតតែត្បុលចូល | ញញឹមយ៉ាងស្រស់ |
| បែបហំថ្លៃថ្នូរ | ស្រែកហ៊ោកកូរ | សូរស័ព្ទក្អាកក្អាយ។ |
| | ដីហុយដូចផ្សែង | |
| ឆ្លប់គ្រប់កន្លែង | ស្លុងលែងឃើញកាយ | អ្នករាំមិនគិត |
| ប្រឹងតែសប្បាយ | មួយយប់មិនណាយ | ដោយចិត្តជ្រះថ្លា។ |
| | ភ្លេងចប់មិនចេញ | |
| ទ្រាំឈរស្នាញស្នេញ | ចំរង់កណ្ដាល | ចាំភ្លេងបទថ្មី |
| មិនខ្ចីវាចារ | ថាហត់កាយា | ឬអស់កំលាំង។ |
| | អត់ធ្មត់យ៉ាងនេះ | |
| សមអ្នកត្រិះរិះ | មិនកាចឆ្លូងឆាំង | តែរាំប៉ះពាល់ |
| មិនទាល់ដាក់ផាំង | កាប់ចាក់ផាក់ច្បាំង | លែងនឹងប្អូនបង។ |
| | ខឹងក្ដៅញ័រមាត់ | |
| បានអ្នកស្រុកឃាត់ | ហក់ចូលញយផង | ខ្លាំងដូចជាខ្លា |

ខឹងផងជេរផង ទើបហត់ញើសខ្នង ព្រោះហក់ចង់វ៉ៃ។
ចង់ឲ្យគេថា
ពូជឯងហានក្លា កាប់ចាក់យសថ្លៃ មិនហ៊ានសម្រួល
ខ្លាចអ្នកស្រុកម៉ែ ថាមានជើងដៃ អន់ខ្សោយអសារ។
ខ្លាំងអើយសែនខ្លាំង
ស៊ូលក់ស្រែប្រាំង បង់តុលាការ ស៊ូរត់ចោលស្រុក
មាតាបិតា ស៊ូចោលសង្សារ ឲ្យតែបានវ៉ៃ។
ស៊ូដេកក្នុងគុក
គ្រាន់ជាងកើតទុក្ខ ព្រោះតែចាញ់ដៃ មានឈ្មោះកំសាក
គេញិចដូចចៃ ដូច្នេះត្រូវវ៉ៃ ស្នងកេរ្តិ៍ឈ្មោះឪ។

សូយ ឡូយ
ភ្នំពេញ ២២កម្ភៈ ២០០៦